# សេចក្ដីសន្និដ្ឋានទៅលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹង ការស៊ើបអង្កេតថ្មីទៅលើអតីតមេដឹកនាំខ្មែរក្រហម

ដោយ ម៉ៃទឹល សាលីបា

ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៩

ប្រែសម្រួលដោយ ជា ផល្លា

នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយទាក់ទងនឹងការមិនយល់ស្របគ្នារវាងព្រះរាជអាជ្ញាជាតិ និងព្រះរាជអាជ្ញាអន្តរជាតិ ដោយបញ្ចប់នូវការរាំងស្ទះរយៈពេល៩ខែដែលពាក់ព័ន្ធនឹងបញ្ហាថា តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវដំណើរការធ្វើស៊ើបអង្កេតបន្ថែមទៅលើអតីតមេដឹកនាំខ្មែរក្រហមដែរឬទេ?

## ប្រវត្តិនៃដំណើរការនីតិវិធី និងច្បាប់ដែលពាក់ព័ន្ធ

ការមិនយល់ស្របគ្នារវាងសហព្រះរាជអាជ្ញាបានកើតឡើងនៅចុងឆ្នាំមុន គឺនៅពេលដែលលោកស្រីសហព្រះរាជអាជ្ញា ជា លាង មិនយល់ស្របនឹងសំណើររបស់អតីតព្រះរាជអាជ្ញាអន្តរជាតិ រ៉ូបឺត ប៉ុទីត ឲ្យដាក់ដីការបញ្ជូនរឿងឲ្យស៊ើបសួរថ្មីពីរទៀត និងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែមមួយទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ដីការបញ្ជូនរឿងឲ្យស៊ើបសួរថ្មីពីរអាចបង្កើតឲ្យមានការជំនុំជម្រះលើករណីទីបី និងទីបួនទៅលើជនត្រូវចោទនៅ អ.វ.ត.ក រីឯដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែមអាចបង្កើតឲ្យមានជនត្រូវចោទទី៥ នៅក្នុងករណី០០២ ដែលក្នុងនោះមានអតីតមេដឹកនាំខ្មែរក្រហមទាំងបួនរូបកំពុងតែរង់ចាំការកាត់ទោស ។ (នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានដកសំណើពីអង្គបុរេជំនុំជម្រះដែលស្នើឲ្យសម្រេចទៅលើការមិនយល់ស្របគ្នាទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែម ពីព្រោះបើយោងទៅតាមការស៊ើបអង្កេតបន្ថែម គឺមានភ័ស្តុតាងបញ្ជាក់ថា ជនសង្ស័យបានស្លាប់បាត់បង់ជីវិតទៅហើយ ។

ដោយមិនអាចដោះស្រាយនឹងការមិនយល់ស្របគ្នា សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បញ្ហាជម្លោះនេះទៅកាន់អង្គបុរេជំនុំជម្រះនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ ។ (សហព្រះរាជអាជ្ញាអន្តរជាតិមិនត្រូវបានគេតម្រូវឲ្យដាក់បញ្ហាជម្លោះទៅអង្គបុរេជំនុំជម្រះទេ ។ តាមការពិត គឺសហព្រះរាជអាជ្ញាទេដែលប្រឆាំងនឹងដីការបញ្ជូនរឿងទៅស៊ើបសួរថ្មី ។ នៅក្នុងករណីនេះ សហព្រះរាជអាជ្ញាជាតិគឺជាអ្នក

ដាក់បន្ទុកទៅលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ នៅក្នុងករណីដែលមិនមានឧបសគ្គបែបនេះ ៣០ថ្ងៃបន្ទាប់ពីទទួលបានដំណឹង សហព្រះរាជអាជ្ញាអន្តរជាតិអាចដំណើរការដីការបញ្ជូនរឿងទៅស៊ើបសួរថ្មីបាន) ។ អនុលោមទៅតាមឯកសារធម្មនុញ្ញរបស់ អ.វ.ត.ក និងវិធានផ្ទៃក្នុងត្រូវតែមានមតិភាគច្រើនលើសលប់គឺចៅក្រម៤ក្នុងចំណោមចៅក្រម៥រូបយល់ស្រប ទើបអាចសម្រេចបាននូវសេចក្ដីសម្រេចបាន ។ (អង្គបុរេជំនុំជម្រះរួមមានចៅក្រមកម្ពុជាបីរូប និងចៅក្រមអន្តរជាតិពីរូប) ។ ក្នុងករណីដែលមិនអាចសម្រេចនូវមតិភាគច្រើនលើសលុប ឯកសារធម្មនុញ្ញរបស់ អ.វ.ត.ក និងវិធានផ្ទៃក្នុងកំណត់ថា ដីកាបញ្ជូនរឿងទៅស៊ើបសួរអាចត្រូវបញ្ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីធ្វើការស៊ើបអង្កេតដោយយុត្តិធម៌ ។

## ការមិនយល់ស្របរបស់សហព្រះរាជអាជ្ញាជាតិ

សហព្រះរាជអាជ្ញាជាតិមិនយល់ស្របនឹងដីកាបញ្ជូនទៅស៊ើបសួរថ្មី ដោយសម្អាងទៅលើមូលហេតុច្បាប់ចំនួនបី ។ ទីមួយ លោកស្រីបានអះអាងថា ដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីគួរតែត្រូវបានប្រានចោល ពីព្រោះការស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិបានរំលោភទៅលើច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ។ ជាក់ស្ដែង លោកស្រីបានអះអាថា លោកស្រីមិនដែលដឹងឬបានពិភាក្សាអំពីអ្វីដែលទាក់ទងនឹងការស៊ើបអង្កេតបឋម ដែលនាំឲ្យមានការចេញដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីឡើយ ។

ទីពីរ លោកស្រីបានអះអាងថា អង្គហេតុ និងឧក្រិដ្ឋកម្មដែលមានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីត្រូវបានដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត តាមរយៈដីកាបញ្ជូនរឿងទៅស៊ើបសួរទីមួយនៅថ្ងៃទី១៨ខែកក្កដាឆ្នាំ២០០៧រួចទៅហើយ ។ លោកស្រីបានអះអាងថា ដីកាបញ្ជូនរឿងទៅស៊ើបសួរ បានគ្របដណ្ដប់ទៅលើគ្រប់ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ អាស្រ័យហេតុនេះ លោកស្រីយល់ថា ដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីគឺមិនមានសារសំខាន់ទេ ពីព្រោះអង្គហេតុនិងឧក្រិដ្ឋកម្មទាំងអស់ កំពុងតែស្ថិតនៅក្នុងអំណាចស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានអំណាចពង្រីកការស៊ើបអង្កេតទៅដល់ជនសង្ស័យផ្សេងទៀត ដែលមិនមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរទីមួយ ។

ជាទីបញ្ចប់ លោកស្រីបានប្រឆាំងដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មី ដោយយោងទៅតាមគោលការណ៍នៃឆន្ទានុសិទ្ធិចោទប្រកាន់របស់លោកស្រី ។ លោកស្រីបានអះអាងថា សេចក្ដីសម្រេចស៊ើបអង្កេតនិងចោទប្រកាន់អតីតមេដឹកនាំខ្មែរក្រហមគួរតែឆ្លើយតបនឹងគោលបំណង និងគោលដៅរបស់

ឯកសារធម្មនុញ្ញរបស់ អ.វ.ត.ក ដែលបង្កើតឡើងដើម្បីជំរុញឲ្យមានសន្តិភាព ស្ថេរភាព និងការផ្សះផ្សាជាតិនៅកម្ពុជា ។ លោកស្រីបានអះអាងថា ជនសង្ស័យដែលត្រូវបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីមិនមែនជាមេដឹកនាំ«ជាន់ខ្ពស់»ខ្មែរក្រហមទេ ។ ជាងនេះទៅទៀត លោកស្រីបានអះអាងថា នៅក្នុងករណីដែលមានការចោទប្រកាន់បន្ថែមកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបអាចនឹងស្ទាក់ស្ទើរ ក្នុងការដើរតួជាសាក្សី ហើយក៏ប្រហែលជាអនុវត្តសកម្មភាពហិង្សាដោយក្លាចនឹងទទួលការចោទប្រកាន់ ។ នៅទីបញ្ចប់ លោកស្រីបានអះអាងថា តុលាការដែលមានស្រាប់អាចនឹងត្រូវទទួលការគំរាមកំហែងពីព្រោះការចោទប្រកាន់បន្ថែមអាចជាបញ្ហាដល់ថវិកានិងធនធានរបស់តុលាការ ។

## ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

ព្រះរាជអាជ្ញាអន្តរជាតិបានជួបខបសគ្គមួយចំនួន ទាក់ទងនឹងពាក្យសុំរបស់សហព្រះរាជអាជ្ញាជាតិ ។ ផ្ទុយពីការអះអាងរបស់លោកស្រី ជា លាង សហព្រះរាជាអាជ្ញាអន្តរជាតិបានអះអាងថា ជនសង្ស័យដែលត្រូវបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មី គឺមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទេ ប៉ុន្តែការចោទប្រកាន់បន្ថែមមានសារសំខាន់ដើម្បីបំពេញនូវអំណាចរបស់ អ.វ.ត.ក ។ (មានការយល់ឃើញថា ជនសង្ស័យដែលនៅរស់ទាំង៥នាក់ដែលត្រូវបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីគឺជាមន្ត្រីជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែមិនកាន់តួនាទីដែលមានឥទ្ធិពល ។

ជាងនេះទៅទៀត សហព្រះរាជាអាជ្ញាអន្តរជាតិបានអះអាងថា ដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីបានលើកឡើងពីអង្គហេតុថ្មី និងបទល្មើសដែលមិនទាន់មាននៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅឡើយ ។ គាត់បានប្រឆាំងនឹងការអះអាងរបស់សហព្រះរាជអាជ្ញាជាតិដែលថា វិសាលភាពនៃបទល្មើស និងអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរលើកទីមួយកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៧ បានគ្របដណ្តប់ទៅលើគ្រប់បទល្មើសដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពិថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ នៅទីបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដោយអនុលោមទៅតាមវិធាន៥៣ លក្ខណៈវិនិច្ឆ័យសំខាន់ដែលត្រូវកំនត់ការស៊ើបអង្កេតថ្មី គឺថាតើមាន«ហេតុផលគួរឲ្យជឿជាក់»បង្ហាញថាបទល្មើសត្រូវបានប្រព្រឹត្តដែរឬទេ?

## សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវបានបែងចែកដោយចៅក្រមជាតិ និងចៅក្រមអន្តរជាតិ

ចៅក្រមកម្ពុជាបីរូបដែលមានឈ្មោះថា ប្រាក់ គឹមសាន, ណី ថុល និង ហួត វុទ្ធី ចេញសេចក្តីសម្រេចយល់ស្របនឹងសហព្រះរាជអាជ្ញាជាតិដោយមូលហេតុថា ការស៊ើបអង្កេតបឋមត្រូវ

បានធ្វើឡើងដោយមិនមានការផ្តល់ដំណឹង ឬពិភាក្សាជាមួយសហព្រះរាជអាជ្ញាជាតិ និងដោយមូលហេតុថាដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីមិនបានលើកឡើងពីបទល្មើស ឬអង្គហេតុបន្ថែមទេ ។ សហចៅក្រមកម្ពុជារកឃើញថា វាមិនមានសារសំខាន់ក្នុងការដោះស្រាយនូវការអះអាង ដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិទាក់ទងនឹងឆន្ទានុសិទ្ធិចោទប្រកាន់ ពីព្រោះចៅក្រមមាន ហេតុផលដ៏មានប្រសិទ្ធិភាពនិងឯករាជ្យពីរ ក្នុងការចេញសេចក្តីសម្រេចយល់ស្របនឹងសហព្រះរាជអាជ្ញាជាតិរួចទៅហើយ ។

ចៅក្រមកម្ពុជាបានកំណត់ថា ការស៊ើបអង្កេតបឋម ត្រូវបានធ្វើឡើងដោយមានការដឹង ឬពិភាក្សាជាមួយសហព្រះរាជអាជ្ញាជាតិ ។ ចៅក្រហមបានលើកឡើងពីអង្គហេតុដែលថានៅពេលដែលសហព្រះរាជអាជ្ញាជាតិដឹងពីការស៊ើបអង្កេតបឋម អតីតសហព្រះរាជអាជ្ញាអន្តរជាតិរ៉ង វីលាម ស្មីត បានប្រាប់លោកស្រីថា លោក«សុំអភ័យទោស»ចំពោះការស៊ើបអង្កេតបឋមដែលធ្វើឡើងភាគីតែម្ខាង ហើយសន្យាថានឹងជូនដំណឹងដល់លោកស្រីប្រសិនបើមានការស៊ើបអង្កេតបន្ថែមទៀត ។ ចៅក្រមកម្ពុជាបានកំណត់ថា ការស៊ើបអង្កេតដែលមានភាគីតែម្ខាង គឺជាការរំលោភទៅលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដូច្នេះលោកសម្រេចច្រានចោលដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មី ។

សហចៅក្រមកម្ពុជាក៏បានកំណត់ថា អង្គហេតុ និងបទល្មើសដែលលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មី គឺមាននៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរលើកទីមួយដែលបានដាក់ទៅការិយល័យស៊ើបអង្កេតរួចទៅហើយ ។ ជាក់ស្តែង សហចៅក្រមកម្ពុជាបានរកឃើញថា ដីកាបញ្ជូនរឿងទៅស៊ើបសួរលើកទីមួយ បានគ្របដណ្តប់ទៅលើគ្រប់ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ទៅហើយ ។ ដូច្នេះចៅក្រមបានសម្រេចថា មិនមានហេតុផលណាត្រូវដាក់ដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មី ពីព្រោះអង្គហេតុ និងបទល្មើសដែលមាននៅក្នុងនោះស្ថិតនៅក្នុងអំណាចស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតរួចទៅហើយ ហើយការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០២ មិនទាន់ត្រូវបានបញ្ចប់នៅឡើយទៀត ។

ចៅក្រមអន្តរជាតិ រ៉ូវ៉ាន់ ដនីង និង កាទីនកា ឡាហ៊ូស បានចេញសេចក្តីសម្រេចយល់ស្របទៅតាមសហព្រះរាជអាជ្ញាអន្តរជាតិដោយសម្អាងលើហេតុផលដែលលើកឡើងដោយចៅក្រមកម្ពុជា ។ ចៅក្រមអន្តរជាតិបានកំណត់ថាបញ្ហានៃការស៊ើបអង្កេតដែលធ្វើឡើងតែភាគីតែម្ខាងមិនជាប់ពាក់ព័ន្ធនឹងការមិនយល់ស្របគ្នារវាងសហព្រះរាជអាជ្ញាទេ ដូច្នេះ វាស្ថិតនៅក្រោយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ។ ចៅក្រមអន្តរជាតិបានធ្វើកំណត់សម្គាល់ថា វិធានផ្ទៃក្នុងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតជាបឋមតែម្នាក់ឯងគឺមិនចាំបាច់មានការយល់ព្រមពីសហព្រះរាជអាជ្ញាទេ ។

យោងទៅតាមការវិភាគទៅលើដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មី និងអង្គហេតុដែលថាការិយាល័យសហព្រះរាជអាជ្ញាបានដាក់ដីកាបញ្ជូនរឿងទៅស៊ើបសួរបន្ថែមមួយចំនួន ដែលដាក់កំហិតទៅលើអង្គហេតុ និងបទល្មើសដែលត្រូវស៊ើបអង្កេតនៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរទីមួយ ចៅក្រមអន្តរជាតិបានកំណត់ថា ដីកាបញ្ជូនរឿងទៅស៊ើបសួរថ្មីមានលក្ខណៈត្រឹមត្រូវសមរម្យ ។ ចៅក្រមបានលើកហេតុផលថា ប្រសិនបើដីកាបញ្ជូនរឿងទៅស៊ើបសួរទីមួយមានលក្ខណៈទូលាយនោះក៏មិនចាំបាច់មានដីកាបញ្ជូនបន្តដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងដីកាបញ្ជូនរឿងទៅស៊ើបសួរបន្ថែមដែលចេញដោយសហព្រះរាជអាជ្ញាដែរ ។ ជាងនេះទៅទៀត ចៅក្រមអន្តរជាតិបានអះអាងថា ដីកាបញ្ជូនរឿងទៅស៊ើបសួរលើកទីមួយមិនអាចមានលក្ខណៈទូលាយ ដែលត្រូវបញ្ចូលគ្រប់បទល្មើសដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ពីព្រោះដីកាបែបនេះនឹងមិនមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ស្របនឹងតម្រូវការរបស់វិធាន៥៣(១) នៃវិធានផ្ទៃក្នុងទេ ។

នៅទីបញ្ចប់ ចៅក្រមអន្តរជាតិបានរកឃើញថាសហព្រះរាជអាជ្ញាជាតិអាចដឹងពីការស៊ើបអង្កេតបឋមនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ និងយល់ច្បាស់ពីសេចក្តីលម្អិតរបស់វានៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ ។ ប៉ុន្តែ លោកស្រីចៅក្រមជាតិរង់ចាំរហូតដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ទើបឆ្លើយតបប្រឆាំងនឹងការស៊ើបអង្កេតបឋម ។ ចៅក្រមអន្តរជាតិបានរកឃើញបញ្ហាដែល មិនមែនជាផ្នែកណាមួយនៃការមិនយល់ស្របគ្នាដែលអង្គបុរេជំនុំជម្រះបានលើកឡើង ដូច្នេះ វាមិនមានសារសំខាន់ក្នុងការពិចារណាថាតើលោកស្រីសហព្រះរាជអាជ្ញាជាតិបានដឹង ឬមិនបានដឹងពីការស៊ើបអង្កេតបឋមនោះទេ ។

## លទ្ធផល និងជំហានបន្ទាប់

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺជាមូលដ្ឋាននៃការស៊ើបអង្កេតដោយយុត្តិធម៌បន្ថែម ។ សហព្រះរាជអាជ្ញាស្តីទី វីលាម ស្មិត មាន«ការពេញចិត្តដែលថាការស៊ើបអង្កេតបន្ថែមអាចបន្តដំណើរការទៅមុខ» ។ ការិយាល័យរបស់លោកនឹង«អនុវត្តតាមសេចក្តីសម្រេច និងចាប់ផ្តើមរៀបចំខ្លួន ដើម្បីជួយដល់សហចៅក្រមស៊ើបអង្កេតក្នុងការស៊ើបអង្កេតឲ្យបានឆាប់រហ័សតាមតែអាចធ្វើបាន» ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងដំណាក់កាលនេះ វានៅតែមានលក្ខណៈលឿនពេកក្នុងការស្ទង់មើលថាតើ និងនៅពេលណាទើបការស៊ើបអង្កេតបែបនេះនឹងឈានទៅដល់ការចោទប្រកាន់បន្ថែម ។

នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេត ទទួលបានដីកាបញ្ជូនរឿងទៅស៊ើបសួរ ការិយាល័យនោះត្រូវតែស៊ើបអង្កេតពីអង្គហេតុ និងបទល្មើសដែលត្រូវចោទប្រកាន់ ។ សាលក្រម

អាចចេញបានលុះត្រាតែការិយាល័យសហចៅក្រមស៊ើបអង្កេតកំណត់ការចោទប្រកាន់ទៅលើជនសង្ស័យដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរ ។ ប្រសិនបើមានការមិនយល់ស្របគ្នារវាងសហព្រះរាជអាជ្ញានិងចៅក្រមនៅអង្គបុរេជំនុំជម្រះ នោះបញ្ហាថាតើត្រូវចោទប្រកាន់ជនសង្ស័យបន្ថែម ឬទេត្រូវវាំងស្ទះនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវវាំងស្ទះដោយចៅក្រមកម្ពុជាម្នាក់ និងចៅក្រមអន្តរជាតិម្នាក់ ។ ដំណើរការនីតិវិធីបំបែកការវាំងស្ទះនៅការិយាល័យសហចៅក្រមស៊ើបអង្កេត មានភាពស្រដៀងគ្នានឹងការបំបែកភាពវាំងស្ទះនៅការិយាល័យសហព្រះរាជអាជ្ញាដែរ ។ នៅក្នុងករណីបែបនេះ ដីកាចាប់ខ្លួនឬឃុំខ្លួន នឹងធ្វើដំណើរទៅមុខប្រសិនបើមានការយល់ស្របតាមមតិភាគច្រើនលើសលប់គឺយល់ស្របដោយចៅក្រម៤នាក់ក្នុងចំណោមចៅក្រម ៥ នាក់ ។

ដោយដឹងពីការមិនយល់ស្របគ្នាជាបន្តបន្ទាប់ទាក់ទងនឹងបញ្ហានេះ រាល់ការចោទប្រកាន់អតីតមេដឹកនាំខ្មែរក្រហមគឺត្រូវចំណាយពេលសម្រាប់អនុវត្ត ។ ខណៈពេលដែលការពន្រ្យាកប្រតិបត្តិការរបស់តុលាការអាចជាឧបសគ្គដល់ធនធានថវិការនៅតុលាការ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានបកស្រាយថា ការបង្កើនពេលវេលា អាចអនុញ្ញាតឲ្យតុលាការមានពេលវេលាផ្តល់ដំណឹងដល់សាធារណៈជនអំពីសកម្មភាពរបស់ខ្លួន ។ អាស្រ័យហេតុនេះ ការបន្ថយ ការព្រួយបារម្ភទាក់ទងនឹងឥទ្ធិពលអាក្រក់អាចប៉ះពាល់ដល់សន្តិភាពនិងស្ថេរភាពនៅក្នុងប្រទេសកម្ពុជា ។

ការស្ទង់មតិដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថា ៥៧ភាគរយនៃប្រជាជននៅក្នុងប្រទេសគាំទ្រការការចោទប្រកាន់បន្ថែម ។ ឆាំង យុ បានបកស្រាយថា ប្រជាជនកម្ពុជា ជំនាន់ក្រោយទំនងជាគាំទ្រឲ្យមានការកាត់ទោសបន្ថែម ប៉ុន្តែប្រជាជនជាច្រើនផ្សេងទៀតចង់ឲ្យតុលាការបំពេញកាតព្វកិច្ចរបស់ខ្លួន និងបញ្ចប់យ៉ាងឆាប់តាមតែអាចទៅរួច ។